# ជំពូក 14 គំរោងកម្មវិធីទ្រទ្រង់

## 14.1 ផែនការកម្មវិធីទ្រទ្រង់

កម្មវិធីទ្រទ្រង់ផលិតកម្មកសិកម្មក្នុងគំរោងស្រោចស្រពនឹងមាន (i)ការពង្រីកសេវាសំរាប់ផ្សព្វផ្សាយបច្ចេកវិទ្យាកសិកម្ម (ii) ការផ្គត់ផ្គង់ និង ការចែកចាយទុនដែលត្រូវការ (iii) ការទ្រទ្រង់ហិរញ្ញវត្ថុឥណទានសំរាប់ទិញទុន និង ការធ្វើវិនិយោគទុន› (iv) ការកែលំអផ្លូវថ្នល់សំរាប់ការដឹកជញ្ជូនផលិតផល និងទុន (v) សកម្មភាពក្រុមកសិករដែលចូលរួម និង ម្ចាស់ការប្រតិបត្តិកម្មវិធីទ្រទ្រង់ ។ ខាងក្រោមនេះបង្ហាញពីដំណើរការកម្មវិធីទ្រទ្រង់:




រូបភាព ដំណើរការផែនការកម្មវិធីទ្រទ្រង់

## 14.2 សេវាផ្សព្វផ្សាយ

### (1) ការផ្សព្វផ្សាយកែលំអបច្ចេកទេសកសិកម្ម

សេវាផ្សព្វផ្សាយកម្មកសិកម្ម គឺមានសារៈសំខាន់ណាស់ដើម្បីធ្វើការផ្សព្វផ្សាយការកែលំអបច្ចេកទេសកសិកម្មទៅអ្នកទទួលការស្រោចស្រព និង ការយល់ដឹងពីផែនការផលិតកម្មដំណាំ ។ គំរោងការស្រោចស្រពគួរតែបានគាំទ្រយ៉ាងពេញទំហឹងដល់សកម្មភាពផ្សព្វផ្សាយដែលធ្វើឡើងដោយមន្ទីរកសិកម្មរុក្ខាប្រមាញ់ និង នេសាទ (DAFF) ។ DAFF គួរតែអនុវត្តការផ្សព្វផ្សាយកសិកម្មអោយបានទូលំទូលាយក្នុងតំបន់គំរោង ។ ក្នុងន័យនេះដែរតំបន់គំរោងបានរៀបចំជាតំបន់គោលដៅអាទិភាពក្នុងសកម្មភាពផ្សព្វផ្សាយផងដែរ ។ សាលាស្រែកសិករ (FFS) គឺជាប្រព័ន្ធផ្សព្វផ្សាយកសិកម្មមួយដ៏មានប្រសិទ្ធិភាពនៅប្រទេសកម្ពុជា ។ ថ្មីៗនេះមន្ទីរកសិកម្មរុក្ខាប្រមាញ់ និង នេសាទ (DAFF) ក្រោមឪវាទក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ (MAFF) បានផ្តល់សេវាផ្សព្វផ្សាយរួមមានវិធានការចំរុះការពារដំណាំ (IPM) តាមរយៈសាលាស្រែកសិករ (FFS) ។ FSS មានគោល បំណងបណ្តុះបណ្តាលគ្រូកសិករ ដែលធ្វើការក្នុងភូមិរបស់គាត់ជាគ្រូស្ម័គ្រចិត្ត ដើម្បីបំរើអ្នកភូមិរបស់គាត់ដោយ ស្ថិតក្រោមឪវាទគណៈកម្មការអភិវឌ្ឍន៍ភូមិ (VDC) ។ FFSs ផ្តល់គោលការណ៍បច្ចេកទេស និង បង្កើតសិក្ខា សាលា ដែលមានអ្នកចូលរួមពីការជ្រើសរើសចេញពី VDCs ។ ជាធម្មតាកសិករចូលរួមមានចំនួន 25 ទៅ 35 នាក់ក្នុងមួយ FFS ដែលធ្វើឡើងក្នុងរយៈពេល16សប្តាហ៍ ដែលសិក្សាទៅលើប្រភេទដំណាំនីមួយៗ ស្រូវ បន្លែ ឬដំណាំបន្ទាប់បន្សំតាមរយៈពេលដាំដុះ ។ មន្ត្រីផ្សព្វផ្សាយ និង គ្រូបង្វឹក IPM ផ្តល់គោលការបច្ចេកទេសទៅ អ្នកចូលរួមតាមរយៈ FFS ។

ក្នុងអំឡុងពេលនោះដែរ FFS បានបង្រៀនមួយឬពីរថ្ងៃជារៀងរាល់សប្តាហ៍ ។ សកម្មភាពភូមិដែលបានបណ្តុះបណ្តាលកសិករដោយ FFS គឺបានជួយទ្រទ្រង់តាមរយៈការងារ និង ត្រួតពិនិត្យ/វាយតំលៃបន្តពីមន្ត្រីផ្សព្វផ្សាយ និង គ្រូបង្វឹករបស់ DAFF ផងដែរ ។ យ៉ាងហោចណាស់កសិករ ដែលបានបណ្តុះបណ្តាលគឺចាំបាច់ក្នុងភូមិនីមួយៗ និង ប្រភេទរបស់ដំណាំគោលដៅ ។ ចំពោះសកម្មភាពការងារកសិករ ដែលបានបណ្តុះបណ្តាលហើយក្នុងភូមិ ការស្រាយបំភ្លឺពីកសិដ្ឋានត្រូវតែមានប្រសិទ្ធិភាពសំរាប់ការស្រាយបំភ្លឺ និងការផ្ទៀងផ្ទាត់ការកែលំអបច្ចេកទេសកសិកម្មចំពោះអ្នកភូមិ ។ ការស្រាយបំភ្លឺកសិដ្ឋានបានបង្កើតឡើងអោយមានក្នុងភូមិដែលមានដំណាំគោលដៅផ្ទៃដីប្រហែល 0.03 ទៅ 0.1ហាត សំរាប់ដំណាំនីមួយៗ ។ ប្រការនេះមានសារៈសំខាន់ណាស់ដែលសកម្មភាពកសិករដែលបានបណ្តុះបណ្តាល គួរធ្វើការសំរបសំរួល និង សហប្រតិបត្តិការបានយ៉ាងល្អជាមួយVDC និងFWUC អំពីប្រព័ន្ធស្រោចស្រព ។




**រូបភាព 12.2 ទំនាក់ទំនងរវាង FFS VDC និង FWUC ក្នុងសកម្មភាពផ្សព្វផ្សាយ**

(2) **ការផ្គត់ផ្គង់ធុន**

ធុនទាំងឡាយដូចជាជីគីមី និង ថ្នាំសំលាប់សត្វល្អិតបាននាំចូលពីប្រទេសជិតខាង ដោយស្ថិតនៅក្រោមគោលនយោបាយសេដ្ឋកិច្ចទីផ្សាររបស់កម្ពុជា ។ នៅពេលបច្ចុប្បន្ននេះទំនងជាធុនទាំងនេះបានផ្គត់ផ្គង់គ្រប់គ្រាន់តាមតំរូវការនៅក្នុងប្រទេស ។ តែទោះបីជាយ៉ាងណាក៏ដោយនៅតំបន់ឆ្ងាយពីគេ ឬស្ថានភាពផ្លូវមិនល្អតំលៃធុនត្រូវឡើងខ្ពស់ដោយសារតែចំណាយការដឹកជញ្ជូនកើនឡើង ។

កសិករភាគច្រើនមិនមានលទ្ធភាពទិញធុនបានទេ ដោយសារស្ថានភាពហិរញ្ញវត្ថុខ្សត់ខ្សោយ ។ ហេតុដូច្នេះហើយកសិករឈប់ទិញធុនទាំងនេះ ឬ ទូទាត់ជាផលិតផលអោយទៅអ្នកលក់វិញ ក្រោយពេលច្រូតកាត់នូវអត្រាការប្រាក់ខ្ពស់ ។

ដើម្បីជំនះបានឧបសគ្គទាំងនេះការកែលំអទីផ្សារ បណ្តាញផ្លូវថ្នល់ និង ក្រុមទិញតាមរយៈក្រុមឥណទាន និង សេចក្តីត្រូវការ ។ ក្រុមទិញសំភារៈតាមរយៈឥណទាន VDC បានបញ្ជាក់ នៅក្នុងអនុផ្នែក 14.3 ។ លទ្ធភាពកែលំអគ្រាប់ពូជស្រូវគឺទាប អាចជាបញ្ហាមួយក្នុងតំបន់គំរោង ។

ក្នុងករណីនេះ ចំពោះផលិតកម្មពូជស្រូវ គួរធ្វើការពិនិត្យជុំវិញតំបន់គំរោងដូចមានខាងក្រោម:

- ភាពប្រាកដប្រជានៃគោលបំណងកសិករ និង កំរិតជំនាញអំពីផលិតកម្មពូជ
- ភាពប្រាកដប្រជានៃការផ្គត់ផ្គង់គ្រាប់ពូជរក្សាទុកបានពីការស្រាវជ្រាវ
- ភាពប្រាកដប្រជានៃការណែនាំបច្ចេកទេសផលិតកម្មគ្រាប់ពូជដោយ DAFF និង ការត្រួតពិនិត្យ និង ការកែច្នៃគ្រាប់ពូជ DAFF ឬក្រុមហ៊ុនផលិតពូជ ។

ក្រុមកសិករ គួរតែរៀបចំក្រុមកសិករផលិតពូជមួយនៅ ក្រោមឱវាទ VDC ឬ CRDC អោយមានប្រសិទ្ធិភាពចំពោះគោលការណ៍ណែនាំបច្ចេកទេស និង ផែនការផលិតគ្រាប់ពូជ ។

## 14.3 ឥណទាន

ក្នុងកម្មវិធីផលិតកម្មកសិកម្មក្រោមប្រព័ន្ធស្រោចស្រព តំរូវការទុននឹងកើនឡើងបើប្រៀបធៀបនឹងស្ថានភាពបច្ចុប្បន្ន ។ ទោះបីជាយ៉ាងណាក៏ដោយ ស្ថានភាពហិរញ្ញវត្ថុកសិករបច្ចុប្បន្នគឺមិនគ្រប់គ្រាន់សំរាប់វិនិយោគទៅលើការទិញសំភារៈធ្វើស្រែបានទេ ។ ប្រព័ន្ធឥណទាន គឺជាប្រព័ន្ធមួយដែលធ្វើអោយកសិករមានលទ្ធភាពទិញទុនកសិកម្មដូចជា គ្រាប់ពូជ ជី ថ្នាំសំលាប់សត្វល្អិត និង អាចវិនិយោគទៅលើគ្រឿងយន្តកសិកម្ម ទីផ្សារផលិតផល ការរក្សាផលិតផលទុក...... ។ល ។

គ្មានប្រព័ន្ធឥណទានស្ថាប័នហិរញ្ញវត្ថុរបស់រដ្ឋាភិបាលនៅប្រទេសកម្ពុជា ។ ជំនួសអោយប្រព័ន្ធឥណទានរបស់រាជរដ្ឋាភិបាល គឺប្រព័ន្ធឥណទានខ្នាតតូចរបស់ NGOs បានក្លាយទៅជាដៃគូដ៏ល្អក្នុងការអភិវឌ្ឍន៍តំបន់ជនបទតាមរយៈការជួយឧបត្ថម្ភពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងម្ចាស់ជំនួយដ៏ទៃទៀត ។ ចំណែកឯប្រព័ន្ធឥណទានកសិកម្មបានសហការណ៍ជាមួយ NGO នានា ជាទូទៅមានសារៈប្រយោជន៏ដោយបានការជួយឧបត្ថម្ភផ្នែកហិរញ្ញវត្ថុដល់អ្នកទទួលផលប្រយោជន៏ ។ ក្រុមឥណទានកសិករ គួររៀបចំនៅ VDC ។ ហើយក្រុមកសិករនេះ ត្រូវប្រមូលប្រាក់ឥណទានត្រលប់មកវិញ ។ ក្រុមនេះគួរបណ្តុះបណ្តាលពីគោលបំណងនៃការគ្រប់គ្រងទឹកប្រាក់ និង ម្ចាស់ការគ្រប់គ្រងនាពេលអនាគត ។ ប្រព័ន្ធឥណទានខ្នាតតូចនៅជនបទមានសារៈសំខាន់ គឺមិនគ្រប់គ្រាន់តែសំរាប់ការទិញទុនកសិកម្មទេ ប៉ុន្តែថែមទាំងជួយក្នុងគោលបំណងផ្សេងៗទៀតដូចជាការវិនិយោគក្នុងជំនួញនៅជនបទ និង ការកែលំអស្ថានភាពផ្ទះសំបែង និង ជីវភាពផងដែរ ។

# ជំពូក 15 សហគមន៍កសិករប្រើប្រាស់ទឹក (ស.ក.ប.ទ)

## 15.1 ច្បាប់ និង ស្ថាប័នពាក់ព័ន្ធ

គោលគំនិតនៃការបង្កើតឡើងនៃសហគមន៍កសិករប្រើប្រាស់ទឹក (ស.ក.ប.ទ) ជាការងារពាក់ព័ន្ធថ្មីមួយនៅក្នុងប្រទេសកម្ពុជា ។ ចាប់តាំងពីការបង្កើតឡើងនូវក្រសួងធនធានទឹក និង ឧត្តុនិយម (MOWRAM) ក្នុងឆ្នាំ 1999 ឯកសារយុទ្ធសាស្ត្រមួយចំនួនដែលជាប់ទាក់ទងទៅនឹងធនធានទឹកត្រូវបានបោះពុម្ពជាបន្តបន្ទាប់ដូចជា :

1) ប្រកាស 306 រួមជាមួយសារាចរលេខ 01 ដែលអនុវត្តន៍នៅលើនយោបាយទ្រទ្រង់ប្រព័ន្ធស្រោចស្រព របស់ក្រសួងធនធានទឹក និងឧត្តុនិយម ខែ មិថុនា 2000
2) រៀបចំការសិក្សានៅលើការបង្កើតឡើងនូវប្រព័ន្ធថ្មីមួយត្រួតពិនិត្យដី និង គ្រប់គ្រងធនធានទឹកក្នុងប្រទេសកម្ពុជា របស់ក្រសួងធនធានទឹក និង ឧត្តុនិយម ខែ មករា 2000
3) គំរោងយុទ្ធសាស្ត្រសំរាប់តំបន់ទឹកនៅក្នុងប្រទេសកម្ពុជា ADB ខែមិនា 2001
4) ពង្រាងយុទ្ធសាស្ត្រ ធនធានទឹករបស់ជាតិ ខែ ឧសភា ឆ្នាំ 2001
5) ពង្រាងច្បាប់ការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ស្ថាប័ន និង ច្បាប់ទាំងនេះគឺសំរាប់ការគិតផែនការនៃការបង្កើតសហគមន៍កសិករប្រើប្រាស់ទឹក ។ ចំណុចសំខាន់ៗមានពី 1 ដល់ 3 និងមានពិពណ៌នាដូចខាងក្រោម ។

(1) ប្រកាស 306 រួមជាមួយសារាចរលេខ 01 នយោបាយសំរាប់និរន្តភាពនៃប្រតិបត្តិការ និង ការថែទាំ (O&M) នៃប្រព័ន្ធស្រោចស្រព និង ដំណាក់កាលនៃការបង្កើត ស.ក.ប.ទ

- ពិនិត្យ និង វាយតំលៃទៅលើគ្រប់ប្រព័ន្ធស្រោចស្រព ដែលមានសក្តានុពលក្នុងប្រសិទ្ធិភាពអភិវឌ្ឍន៍របស់សេដ្ឋកិច្ចជាតិ ។
- សារាចរលេខ 01 បានធ្វើអោយមានលក្ខណៈស្តង់ដារនូវលក្ខន្តិកៈ របស់សហគមន៍កសិករប្រើប្រាស់ទឹក ។
- ដើម្បីធ្វើការសិក្សាដែលអាចធ្វើបាន ហើយនិងសាងសង់ប្រព័ន្ធស្រោចស្រព ដើម្បីផ្គត់ផ្គង់ទឹកដល់ដីកសិករក្នុងលក្ខណៈនិរន្តភាព និង ទទួលផលល្អ ។
- ដើម្បីសហប្រតិបត្តិការជាមួយនិងក្រសួងដែលពាក់ព័ន្ធដើម្បីទ្រទ្រង់សហគមន៍កសិករប្រើប្រាស់ទឹក ។ នយោបាយសំរាប់និរន្តភាព O&M នៃប្រព័ន្ធស្រោចស្រពដែលយោងទៅលើគោលគ្រឹះសំខាន់ៗដូចជា :
- លក្ខន្តិកៈស្របច្បាប់នៃសហគន៍កសិករប្រើប្រាស់ទឹក (FWUC)
- ការជាប់ទាក់ទងរបស់ FWUC ក្នុងការអភិវឌ្ឍន៍ប្រព័ន្ធ
- កាតព្វកិច្ចរបស់កសិករក្នុងការទូទាត់តំលៃ O&M និង តំលៃសំរាប់ការងារបន្ទាន់របស់ O&M
- ការជួសជុលជាប្រចាំ និង កែលំអប្រព័ន្ធស្រោចស្រពដែលមានស្រាប់
- ចាត់ចែងការផ្តល់ទឹកជាសមភាព និង ប្រសិទ្ធិភាព និង

- ទទួលបានការគាំទ្រ និង ជំនួយផ្សេងៗពី ក្រ.ធ.ទ.ឧ នូវបច្ចេកទេសជួសជុល ការគ្រប់គ្រងពិនិត្យ និង វាយតំលៃ ។ល។ ដំណាក់កាលទាំងអស់នៅក្នុងការបង្កើត ស.ក.ប.ទ មួយដែលពិពណ៌នាពីភាពផ្សេងៗគ្នានៃដំណើរការបង្កើត ស.ក.ប.ទ ។ នយោបាយនេះគឺសំដៅដល់ការផ្ទេរ ការទទួលខុសត្រូវក្នុងការគ្រប់គ្រងលើ FWUCs ។ FWUCs ត្រូវតែជាយន្តការដែលមិនមែនជាស្ថាប័នរកចំណូលមួយ ។ ស្ថាប័នទាំងនេះជាអ្នកបំរើអោយការងារប្រតិបត្តិការនៅក្នុងសហគមន៍ទាំងអស់ ។

(2) រៀបចំការសិក្សាទៅលើការបង្កើតឡើងនូវប្រព័ន្ធត្រួតពិនិត្យថ្មីមួយលើផ្ទៃដី និង ការគ្រប់គ្រងធនធានទឹកនៅក្នុងប្រទេសកម្ពុជា ខែ មករា ឆ្នាំ 2000 ។

ឯកសារនេះត្រូវបានបោះពុម្ពផ្សាយភ្លាមៗ បន្ទាប់ពីមានការបង្កើតឡើងនូវក្រសួងធនធានទឹក និងឧតុនិយម ហើយរួមបញ្ចូលលើផ្នែកនៃប្រតិបត្តិការ និង ការគ្រប់គ្រងនៃគំរោងស្រោចស្រព ។ ក្រុមនៃប្រព័ន្ធស្រោចស្រពគឺត្រូវបានរួមបញ្ចូល ហើយការធានាខុសត្រូវលើការគ្រប់គ្រងត្រូវបានបង្កើតដូចខាងក្រោម :

(3) គំរោងការយុទ្ធសាស្ត្រសំរាប់ទឹកក្នុងប្រទេសកម្ពុជា គំរោងយុទ្ធសាស្ត្រនេះបានបោះពុម្ពក្នុងខែ មិនា 2001 ពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ក្នុងការបង្កើតសមត្ថភាពគំរោង ។ បញ្ហាសំខាន់ៗដែលត្រូវបានរាប់

**<u>ចំណាត់ថ្នាក់នៃគំរោងស្រោចស្រព</u>**

<u>ខ្នាតតូច</u>

តិចជាង 200 ហ.ត ដែលគ្រប់គ្រងដោយមន្ទីរស្រុក ។ បើពាក់ព័ន្ធច្រើនជាងមួយស្រុក DWRAM ជាអ្នកទទួលខុសត្រូវលើការគ្រប់គ្រង ។O& M ជាការទទួលខុសត្រូវរបស់ FWUCs ។

<u>ខ្នាតមធ្យម</u>

ចន្លោះ 200-500 ហ.ត គ្រប់គ្រងដោយ DWRAM ។ បើមានជាប់ពាក់ព័ន្ធលើសពីមួយខេត្ត MOMRAM ជាអ្នកទទួលខុសត្រូវសំរាប់ការគ្រប់គ្រងគំរោង ។

<u>ខ្នាតធំ</u>

ច្រើនជាង 5000 ហ.ត គ្រប់គ្រងដោយ MOWRAM

បញ្ចូលគឺ ការបង្កើតនូវយុទ្ធសាស្ត្រងាយស្រួលយល់សំរាប់ការស្រោចស្រព និង ដោះទឹកដែលរួមមានដូចជា :

- លើកទឹកចិត្តដល់កសិករគ្រប់គ្រងគំរោង
- លើកទឹកចិត្តដល់ផ្នែកឯកជនដែលជាប់ពាក់ព័ន្ធ
- បង្កើតឡើងនូវនិរន្តភាព
- ធានាបាន នូវទ្រព្យសម្បត្តិស្របច្បាប់នៅលើដី និង ទឹក
- ការចូលរួមពីអ្នកដែលជាប់ទាក់ទងក្នុង O&M នៃប្រព័ន្ធស្រោចស្រព និង ប្រព័ន្ធដោះទឹក
- ព្យាករណ៍នូវការប៉ះពាល់បរិស្ថាន និង
- សិទ្ធិនៃការប្រើប្រាស់ទឹក ។

## 15.2 រចនាសម្ព័ន្ធរបស់សហគមន៍កសិករប្រើប្រាស់ទឹក

ការអភិវឌ្ឍន៍ការស្រោចស្រព ការស្តារឡើងវិញ រឺ ការពង្រីកកម្មវិធីទាំងឡាយ នឹងត្រូវអនុវត្តន៍នៅលើមូលដ្ឋានអាចធ្វើបាន និង ភាគច្រើនជាកសិករ ។ ការចូលរួមដ៏ពេញលេញរបស់អ្នកប្រើប្រាស់នឹងត្រូវប្រកាន់យកទៅលើគ្រប់គំរិតទាំងអស់ដែលត្រូវចាប់ផ្តើមចាប់តាំងតែពីពេលដំបូង ។ ការបង្កើត FWUC នឹងត្រូវតែចាប់ផ្តើមពីការងារបឋមដែលនាំទៅដល់ការអនុវត្តន៍របស់គំរោងស្រោចស្រព ។ នៅពេលការបញ្ចប់គំរោង ការទទួលខុសត្រូវលើប្រតិបត្តិការ និង ការថែទាំ ព្រមទាំងការជួសជុលបន្ទាន់នឹងទុកឱ្យ FWUC ដំណើរការបន្តិចម្តងៗ ។ យោងទៅលើសមត្ថភាពនៃអង្គការកសិករ គំរោងស្រោចស្រពទាំងឡាយនឹងត្រូវផ្ទេរទៅអោយ FWUCs សំរាប់និរន្តភាពប្រត្តិបត្តិការ និង ការថែទាំរបស់ពួកគេ ។ សិទ្ធិក្នុងប្រត្តិបត្តិការនៃការផ្ទេរគំរោង និង ហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធដទៃទៀត ព្រមទាំងការទទួលខុសត្រូវក្នុងការការពារនឹងត្រូវស្ថិតនៅជាមួយនឹង FWUC ដែលទទួលស្គាល់ដោយរដ្ឋាភិបាល ។ យោងលើប្រកាស 306 ដែលរៀបរាប់ក្នុងផ្នែកខាងមុខ បន្ទាប់ពីគំរោង ត្រូវបានផ្ទេរទៅអោយនាយកដ្ឋានស្រោចស្រពកសិកម្មនៃក្រសួងធនធានទឹក និង ឧតុនិយម នឹងត្រូវបញ្ចូលនូវកិច្ចព្រមព្រៀងចាំបាច់ផ្សេងៗជាមួយសមាគមន៍កសិករប្រើប្រាស់ទឹកសំរាប់ការប្រើ និង សំរាប់ការប្រើប្រាស់ដ៏សមរម្យនូវឧបករណ៏ស្រោចស្រព និង ហេដ្ឋារចនាសម្ព័ន្ធដទៃទៀត ។ FWUC នឹងត្រូវគ្រប់គ្រងដោយគណៈកម្មាការរបស់ពួកគេដែលបានបោះឆ្នោតដោយសមាជិករបស់ FWUC ។ ជាគោលការណ៍ គណៈកម្មការមានសមាជិកដូចខាងក្រោម :

**<u>សមាជិកគណៈកម្មការសហគមន៍កសិករប្រើប្រាស់ទឹក</u>**

- ប្រធាន 1 រូបទទួលបន្ទុកការត្រួតពិនិត្យទូទៅ
- អនុប្រធានទី 1 ម្នាក់ទទួលបន្ទុកការងារថែទាំ និង ផែនការជួសជុល
- អនុប្រធាន ទី 2 មួយរូបទទួលបន្ទុកការងារចែកចាយ និង តំកល់ឯកសារ
- ហិរញ្ញិកមួយរូបទទួលបន្ទុកការងារហិរញ្ញវត្ថុ
- ប្រធានក្រុមកសិករប្រើប្រាស់ទឹកទាំងអស់ (ស.ក.ប.ទ)

គណកម្មការមានភារកិច្ចដូចតទៅ :

**<u>ភារកិច្ចរបស់គណៈកម្មការ ស.ក.ប.ទ</u>**

- ចាត់ចែងកម្មវិធីការងាររបស់សហគមន៍
- តួនាទីការងារទៅតាមលក្ខន្តិកៈរបស់សហគមន៍ដែលបានចូលរួមសំរេចដោយសហគមន៍កសិករប្រើប្រាស់ទឹក និង ក្រសួងធនធានទឹក និង ឧតុនិយម ។
- ចាត់ចែង O & M នៃប្រព័ន្ធស្រោចស្រពដើម្បីសន្សំសំចៃការប្រើប្រាស់ទឹកឱ្យបានប្រសើរ
- ដោះស្រាយវិវាទនៅក្នុងចំណោមសមាជិកសមាគមន៍
- ប្រមូលវិភាគទានថ្លៃសេវាប្រើប្រាស់ទឹក (ISF) ដែលសំរេចដោយសហគមន៍
- ការកំណត់គំរិត អំណាច និង ការទទួលខុសត្រូវរបស់ FWUC សំរាប់ផែនទីភូមិសាស្ត្រតាមតំបន់នីមួយៗ និង ប្រភេទគំរោងដែលបានរៀបចំដោយក្រសួងធនធានទឹក និង ឧតុនិយម ។

សហគមន៍កសិករប្រើប្រាស់ទឹក និងមានអ្នកតំណាងកសិកររបស់ខ្លួនពីគ្រប់គិរិតនៃប្រព័ន្ធស្រោចស្រព (ផ្លូវទឹកហូរ ប្រឡាយចែកចាយទឹក ប្រឡាយរង និង ប្រឡាយមេ) ឬ ក.ស.ក.ប។ ក.ក.ប.ទ គឺបង្កើតចេញពីកសិករដែលប្រើប្រាស់ទឹកនៅក្នុងតំបន់ស្រោចស្រពតែមួយ ។ ការបង្កើតក្រុម និង យោងទៅលើស្ថានភាពភូមិសាស្ត្ររបស់ដីកសិដ្ឋានព្រមទាំងព្រំប្រទល់នៃប្រព័ន្ធស្រោចស្រពនៅក្នុងតំបន់នោះ ។ ក្រុមនីមួយៗ ត្រូវបានដឹកនាំដោយអ្នកដឹកនាំម្នាក់តាមរយៈការបោះឆ្នោតដោយសមាជិកទាំងអស់ ឬ ក៏អ្នកតំណាងទាំងអស់ ហើយអាចនឹងមានអ្នកជំនួយការប្រសិនបើចាំបាច់ ។

ក្រុមកសិករប្រើប្រាស់ទឹកមានភារកិច្ចដូចតទៅ :

**ភារកិច្ចរបស់ក្រុមកសិករប្រើប្រាស់ទឹក**

- អ្នកអនុវត្តន៍នូវកម្មវិធីការងាររបស់សហគមន៍ ។ ផ្តល់នូវទិន្នន័យសំរាប់ផែនការ និង ការរៀបចំ ។
- សំរបសំរួលរវាងសមាជិកក្រុមកសិករប្រើប្រាស់ទឹក និង សហគមន៍
- ប្រមូលថ្លៃសេវាស្រោចស្រពពីសមាជិកទៅតាមពេលវេលាកំណត់ ។

**រូបភាព. 15.1 បង្ហាញពីស្តង់ដារចនាសម្ព័ន្ធរបស់សហគមន៍កសិករប្រើប្រាស់ទឹក**

## 15.3 ការបង្កើតសហគមន៍ប្រើប្រាស់ទឹក

### 15.3.1 លក្ខណៈទូទៅ

គុណភាពនៃសេវាទឹកដែលនឹងត្រូវផ្តល់ឱ្យបន្ទាប់ពីបញ្ចប់គំរោងស្រោចស្រព និង លក្ខខ័ណ្ឌនៃការមិនពេញចិត្តខ្លះៗ បើមិនមានការថែទាំ និង ការគ្រប់គ្រងអោយបានត្រឹមត្រូវ ។ ក្នុងដំណាក់កាលប្រត្តិបត្តិការគំរោងនឹងជួបនូវបញ្ហាខ្វះខាតទឹក ប្រព័ន្ធដោះទឹកមិនល្អ ការប្រើប្រាស់ទឹកដោយគ្មានការអនុញ្ញាតិរបស់កសិករ គ្មានតុល្យភាពនៃការចែកចាយទឹកពីផ្នែកខាងដើម និង ចុងប្រព័ន្ធនឹងគ្មានការយកលំនាំតាមនៃបំលាស់ប្តូរគំរូដាំដុះ ។ លទ្ធផលនៃភាពយ៉ាប់យ៉ឺនរបស់ហេដ្ឋានរចនាសម្ព័ន្ធនានា នឹងធ្វើឱ្យតំលៃឡើងខ្ពស់ និង ផលិតភាពទាបដែលផ្ទុយនឹងផលប្រយោជន៍របស់គំរោងដែលបានព្យាករណ៍ និង វិធីនៃនិតិបញ្ញាតិបឋមនៃប្រភពធនធានទឹកនឹងពឹងផ្អែកទៅលើរដ្ឋាភិបាល ។

ភាពជោគជ័យរបស់ប្រព័ន្ធនៃការគ្រប់គ្រង នឹងពុំមែនសំរាប់ការខិតខំប្រឹងប្រែងក្នុងការគ្រប់គ្រងផ្ទាល់ដោយអ្នកប្រើប្រាស់ទេ ។ អាស្រ័យហេតុនេះជាមួយនឹងគោលគំនិតចូលរួមរបស់កសិករនៅក្នុងការគ្រប់គ្រងប្រព័ន្ធស្រោចស្រព កសិករនឹងបង្កើតឡើងនូវសហគមន៍កសិករប្រើប្រាស់ទឹក ដើម្បីគ្រប់គ្រងការងាររបស់ពួកគេ ។ ក្រោមនយោបាយរបស់រដ្ឋាភិបាល គំរោងស្រោចស្រពនឹងត្រូវផ្ទេរទៅអោយសហគមន៍កសិករប្រើប្រាស់ទឹកសំរាប់និរន្តភាពនៃប្រតិបត្តិការ និង ការថែទាំ ព្រមទាំងដើម្បីលើកកំពស់ការស្រោចស្រពកសិកម្មអាស្រ័យទៅលើសមត្ថភាពនៃសហគមន៍នីមួយៗ ។ សហគមន៍កសិករប្រើប្រាស់ទឹក និង រដ្ឋាភិបាល នឹងត្រូវរួមគ្នាគ្រប់គ្រងប្រព័ន្ធស្រោចស្រពដែលមិនប្រគល់អោយផ្តាច់ឡើយ ។ អង្គការរបស់អ្នកទទួលផលប្រយោជន៍ និង គ្រប់គ្រងប្រត្តិបត្តិការ និង ការថែទាំប្រព័ន្ធ នឹងហៅថាសហគមន៍កសិករប្រើប្រាស់ទឹក ។

### 15.3.2 សារៈប្រយោជន៍នៃសហគមន៍កសិករប្រើប្រាស់ទឹក :

សារៈប្រយោជន៍នៃអ្នកទទួលផលប្រយោជន៍របស់ FWUC នឹងបង្ហាញដូចតទៅ :

- ធានា និង ការទុកចិត្តបានក្នុងការទទួលទឹកតាមកិច្ចព្រមព្រៀងក្នុងរយះពេលយូរយោងទៅលើស្នាក់ការស្រោចស្រព និង សិទ្ធិក្នុងការរក្សាទឹកទុកដោយខ្សែក
- ភាពសោមនស្សនៃការទុកចិត្តខ្លួនឯង និង ស្មារតីក្នុងការគ្រប់គ្រងប្រព័ន្ធដោយខ្លួនឯងផ្ទាល់
- ការបន្ថយការបាត់បង់ក្នុងប្រត្តិបតិការ និង ការខ្ជះខ្ជាយ និង លទ្ធផលក្នុងការបង្កើតប្រសិទ្ធិភាពស្រោចស្រព
- បង្កើតឡើងនូវផ្ទៃដីដាំដុះតាមរយៈការស្រោចស្រពទឹកដោយលក្ខណៈសន្សំសំចៃ និង តាមមធ្យោបាយកាត់បន្ថយថ្លៃទឹកក្នុង 1 ហ.ត
- សមភាពក្នុងការទទួលទឹកក្នុងករណីខ្វះខាតទឹកក្នុងចំនួនផ្គត់ផ្គង់នៃប្រព័ន្ធ
- គ្រប់គ្រងវិវាទបានប្រសើរ
- អ្នកប្រើប្រាស់ទាំងអស់នៅក្នុងក្រុមកសិករប្រើប្រាស់ទឹកត្រូវទូទាត់ទឹកដែលប្រើពិតប្រាកដក្នុង 1 ហ.ត យោងលើស្ថានភាពនៃការដាំដុះជាក់ស្តែង ។
- ធានានូវការទទួលទឹកដល់កសិករនៅផ្នែកខាងចុងប្រព័ន្ធ
- គ្រប់គ្រងនូវការប្រមូលទឹកជាមួយនឹងផែនការដាំដុះ នៅក្នុងការពិចារណាទៅលើស្ថានភាពទីផ្សារ ហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ បរិមាណទឹកស្តុក និង ការដឹកជញ្ជូននឹងជាលទ្ធផលដ៏ប្រសើរសំរាប់អ្នកប្រើប្រាស់
- សមាជិកទាំងអស់អាចចូលរួមសំរេចក្នុងផែនការ និង ការរៀបចំប្រព័ន្ធព្រមទាំងចូលរួមក្នុងការសាងសង់ជួសជុល និង ថែទាំសំរាប់ប្រសិទ្ធិភាពនៃការប្រើប្រាស់ទឹក ។
- សមាជិកទាំងអស់អាចធ្វើសំណើកែប្រែ កែលំអប្រព័ន្ធគ្រប់គ្រង និង កម្មវិធីផ្តល់ទឹកក៏ដូចជាចូលរួមក្នុងការសំរេចនៅក្នុងកិរិតរបស់គំរោង
- តាមរយៈ FWUC សមាជិកទាំងអស់អាចទទួលនូវសេវាផ្សេងៗនៃនាយកដ្ឋានដែលពាក់ព័ន្ធនឹងការអភិវឌ្ឍន៍កសិកម្មនៅក្នុងកិច្ចសហប្រតិបត្តិការមួយតាមរយៈការផ្តល់យោបល់របស់ពួកគេ និងការណែនាំ ។

### 15.3.3 ការបង្កើតសហគមន៍កសិករប្រើប្រាស់ទឹក (FWUC)

សេចក្តីកំណត់ច្បាស់របស់ FWUC នឹងត្រូវយោងលើព្រំប្រទល់ជលសាស្ត្រ ដែលជំនួសអោយព្រំប្រទល់ភូមិ ។ ក្នុងការស្តារឡើងវិញនូវប្រព័ន្ធស្រោចស្រព កសិករទាំងអស់បានយល់ដឹងពីតំបន់ស្រោចស្រព មុននឹងប្រព័ន្ធត្រូវបានរិចរិល ឬ បំផ្លាញដែលបណ្តាលមកពីបទពិសោធន៍កន្លងមក ។ គោលសំខាន់នៃការបង្កើតឡើងនូវសកម្មភាព នឹងត្រូវស្ថិតនៅក្នុងប្រឡាយចែកចាយ (ស្រោចស្រព) ឬក៏កិរិតនៃផ្លូវទឹក ។ សហគមន៍កសិករប្រើប្រាស់ទឹកមួយនឹងត្រូវបង្កើតឡើងដើម្បីគ្រប់គ្រងនៅលើប្រលាយចែកចាយទឹកទាំងមូល និង គ្រប់កិរិតស្ថាប័ន និង ត្រូវរៀបចំឡើងអាស្រ័យទៅលើទំហំនៃប្រព័ន្ធស្រោចស្រព ។ យោងទៅលើដំណាក់ការនៃការ

បង្កើតសហគមន៍មួយដែលរៀបចំឡើងដោយក្រសួងធនធានទឹក និង ឧត្តុនិយម ការបង្កើត FWUC គឺជាប្រព័ន្ធរចនាសម្ព័ន្ធមួយ នឹងបង្កើតឡើងតាមដំណាក់កាលជាបន្តបន្ទាប់ ។ ក្រសួងធនធានទឹក និង ឧត្តុនិយម តាមរយៈនាយកដ្ឋានស្រោចស្រពកសិកម្ម នឹងផ្តល់នូវបច្ចេកទេស និង គាំទ្រដល់ការគ្រប់គ្រងនៅក្នុងការបង្កើតសមាគមន៍កសិករប្រើប្រាស់ទឹក ។

(1) **ចំណាក់កាលទី 1: " ព្រំប្រទល់ផ្ទៃដី និង ការយល់ឃើញរបស់កសិករ "**

ព្រំប្រទល់នៃតំបន់ស្រោចស្រពគឺជាទង្វើដំបូងបំផុតអស្រ័យទៅលើទឹកស្រោចស្រពដែលមាន និង ព្រំប្រទល់ជលសាស្ត្រ ។ បណ្តាឃុំជាបន្តបន្ទាប់ ឬ វេទិកា ភូមិ ឬ ក៏ការប្រជុំសាធារណៈ នឹងធ្វើឡើងជាបន្តបន្ទាប់នៃការចាប់ផ្តើម ។ នៅក្នុងវេទិកា ទាំងនេះ គោលដៅសំខាន់ និង វត្ថុបំណងទាំងអស់នៃកម្មវិធីក៏ដូចជាសកម្មភាពជាសារវ័ន្តផងដែរនឹងត្រូវជូនដំណឹងដល់កសិករទាំងអស់ ។ គោលបំណងរបស់វេទិកា ទាំងនេះគឺដើម្បីជូនដំណឹងលំអិតដល់អ្នកប្រើប្រាស់អំពីសកម្មភាពទាំងអស់នេះនាពេលអនាគត ដើម្បីបញ្ជាក់ឱ្យច្បាស់ថាប្រព័ន្ធស្រោចស្រពនឹងគ្រប់គ្រងដោយកសិករ ហើយសេចក្តីត្រូវការរបស់កសិករ គណៈកម្មការនឹងបានរកឃើញនៅក្នុងការប្រជុំទាំងអស់នេះ ។

(2) **ចំណាក់កាលទី 2: "ការកំណត់ពិត"**

វាគឺជាការចាំបាច់ដែលត្រូវធ្វើឱ្យយល់នូវទ្រង់ទ្រាយនៃប្រព័ន្ធស្រោចស្រពទាំងមូល ដើម្បីជួយដល់កសិករទាំងអស់នៅក្នុងការបង្កើត ស.ក.ប.ទ ។ ស.ក.ប.ទ ទទួលខុសត្រូវគ្រប់គ្រង ប្រព័ន្ធស្រោចស្រពចេញពីក្បាលហុងទឹកទៅផ្នែកខាងក្រោយបំផុតនៃប្រលាយទាំងអស់ ។ ប្រសិនបើប្រព័ន្ធស្រោចស្រពមានភាពធំពិតប្រាកដជាទូទៅនឹងត្រូវការដើម្បីអភិវឌ្ឍន៍នូវក្រុមកសិករប្រើប្រាស់ទឹកតូចៗនៅថ្នាក់ក្រោម ។

(3) **ចំណាក់កាលទី 3: "ការបង្កើតក្រុមប្រឹក្សាសហគមន៍កសិករប្រើប្រាស់ទឹក"**

នៅក្នុងការបង្កើតសហគមន៍កសិករប្រើប្រាស់ទឹក យោងទៅលើឯកសារនៃការបោះឆ្នោតដោយសមាជិកទាំងអស់នៃតំណាងក្រុមប្រឹក្សារបស់កសិករទាំងអស់នៅក្នុងតំបន់ប្រព័ន្ធស្រោចស្រព គឺជាការអនុវត្តន៍ធម្មតា ។ នៅក្នុងប្រព័ន្ធស្រោចស្រពធំៗ វាគឺជាដំបូន្មានមួយសំរាប់ដំណើរការដឹកនាំទម្រង់ការប្រតិភូបានមកពីការបោះឆ្នោតក្នុងតំបន់ ។ សារៈសំខាន់របស់ក្រុមប្រឹក្សារបស់ ស.ក.ប.ទ វាជាការអង្កេតមើលក្នុងរយៈពេលនៃការថែទាំត្រួតពិនិត្យ និង តុល្យភាព នៅក្នុងសកម្មភាពទាំងឡាយរបស់ ស.ក.ប.ទ ។ ការទទួលខុសត្រូវទាំងអស់របស់ ស.ក.ប.ទ គឺជាការកំនត់នូវកំរិតទឹក ការអភិវឌ្ឍន៍នឹងអោយសច្ចាប័នទៅលើរចនាសម្ព័ន្ធ ស.ក.ប.ទ ការបោះឆ្នោតសមាជិករបស់ ស.ក.ប.ទ ព្រមទាំងការពិនិត្យពិច្ច័យ និងអនុម័តថវិកា និង ការចំណាយ ។ ពង្រាងលក្ខន្តិកៈគណៈកម្មការអាចបង្កើតចេញពីសហគមន៍នីមួយៗក្រោយសំណើនៃតំបន់ស្រោចស្រព ។

(4) **ចំណាក់កាលទី 4: "ការជ្រើសរើសអ្នកទាក់ទងកសិករ (FO)"**

អាស្រ័យលើការទ្រទ្រង់នៃប្រព័ន្ធស្រោចស្រព ប្រព័ន្ធទាំងមូលនឹងចែកជាប្លុកស្រោចស្រពជាច្រើន ។

FO នឹងត្រូវបានជ្រើសចេញពីស្រទាប់ប្រជាជននៅក្នុងប្លុកស្រោចស្រព (គឺ 50-100ហ.ត) ។ តួនាទីរបស់ FO គឺការបង្កើតឡើងនូវ ស.ក.ប.ទ និង ការប្រមូលពត៌មានពីកសិករ និង កំណត់ត្រាផ្សេងៗ ។ ក្រុម FOs ទាំងអស់ដែលបានជ្រើសតាំងនិងត្រូវបណ្តុះបណ្តាលតួនាទីរបស់ពួកគេ និង ដំណើរការនៃការបង្កើត ស.ក.ប.ទ ។ល។

(5) **ដំណាក់កាលទី 5: "ការពិភាក្សាពង្រាងលក្ខន្តិកៈ ស.ក.ប.ទ"**

ដើម្បីបញ្ជាក់ការចុះបញ្ជីគណៈកម្មការ ស.ក.ប.ទ ជាមួយ រដ្ឋាភិបាល វាជាសំណើ ដើម្បីបង្កើតពង្រាងលក្ខន្តិកៈ ស.ក.ប.ទ មួយឈានទៅផ្តល់តួនាទីរបស់ ស.ក.ប.ទ ។ ពង្រាងលក្ខន្តិកៈគណៈកម្មការអាចបង្កើតឡើងចេញពីតំបន់នីមួយៗដែលបញ្ជាក់ក្នុងដំណាក់កាលទី 4 ។ យោងទៅលើពង្រាងលក្ខន្តិកៈ ដែលរៀបចំដោយរដ្ឋាភិបាល ពង្រាងគណៈកម្មការ និង ពិភាក្សាពីបញ្ញត្តិធ្វើការកែប្រែចាំបាច់ និង ទីបញ្ចប់បញ្ជូនសំរាប់ចុះសច្ចាប័ននៅក្នុងការប្រជុំក្រុមប្រឹក្សា ស.ក.ប.ទ ។

(6) **ដំណាក់កាលទី 6: "ការបង្កើតប្រព័ន្ធនៃ ស.ក.ប.ទ"**

ដំណើរការនៃការបង្កើត ស.ក.ប.ទ វាជាការផ្តើមសំខាន់លើព្រំប្រទល់ជលសាស្ត្រ នៃប្រព័ន្ធដែលចេញពីផ្លូវទឹក និង ស្រោចស្រពទៅដល់គីឡូនៃប្រលាយមេ ។ គណៈកម្មការជាន់ខ្ពស់ គឺបង្កើតឡើងដោយប្រព័ន្ធរចនាសម្ព័ន្ធតាមថ្នាក់ៗ ពីថ្នាក់ទាបបំផុតរបស់ ក.ក.ប.ទ ។ ជាមួយគ្នានេះដែរ ការយល់ដឹងត្រឹមត្រូវពីដំណើរការនឹងផ្តល់ចំពោះអ្នកដែលបានទទួលផលប្រយោជន៍ទាំងស្រុង ។

(7) **ដំណាក់កាលទី 7: "ការចុះសច្ចាប័នចុងក្រោយអំពីតួនាទីរបស់ ស.ក.ប.ទ"**

បន្ទាប់ពីគណៈកម្មការ និង ក្រុមប្រឹក្សា ស.ក.ប.ទ ត្រូវបានបង្កើតឡើងពង្រាងសច្ចាប័នចុងក្រោយអំពីតួនាទីរបស់ ស.ក.ប.ទ អាចនឹងប្រាស្រ័យជាមួយនិងជំនួយរបស់ FOs និង បុគ្គលិករដ្ឋាភិបាល ។

វាជាប្រការសំខាន់មួយដែលក្រុមប្រឹក្សានៃ ស.ក.ប.ទ បានពាក់ព័ន្ធនៅក្នុងដំណើរការនៃសច្ចាប័ន ដូច្នេះពង្រាងគណៈកម្មការអាចដើរតួនាទីដ៏សកម្មមួយនៅក្នុងពង្រាងជាក់លាក់ និង ដំណើរការកែតំរូវពង្រាង ។

(8) **ដំណាក់កាលទី 8: "ការចុះបញ្ជីនូវលក្ខន្តិកៈ និង គណៈកម្មការ ស.ក.ប.ទ"**

ជាមួយនិងដំណាក់កាលខាងលើទាំងអស់ ស.ក.ប.ទ នឹងត្រូវបានបញ្ចប់ក្នុងគីឡូផ្សេងៗនៃប្រព័ន្ធស្រោចស្រព និង ដំណើរការលក្ខន្តិកៈ ។ គណៈកម្មការ ស.ក.ប.ទ បន្ទាប់មកនឹងស្នើរទៅដល់ភ្នាក់ងាររបស់រដ្ឋាភិបាលដែលពាក់ព័ន្ធសំរាប់ការចុះបញ្ជី ដើម្បីនឹងបង្កើតឡើងនូវតួនាទីស្របច្បាប់មួយនៃ ស.ក.ប.ទ នឹងត្រូវទទួលបាននូវការណែនាំពីកិច្ចព្រមព្រៀងជាមួយក្រសួងធនធានទឹក និង ឧតុនិយម ។ ភ្នាក់ងារដែលពាក់ព័ន្ធទាំងអស់ក្រោមឱវាទក្រសួងធនធានទឹក និង ឧតុនិយម ។ បន្ទាប់ពីពិនិត្យមើលនូវលក្ខន្តិកៈ និង ដំណើរការបង្កើត ស.ក.ប.ទ នឹងត្រូវផ្តល់វិញ្ញាបនប័ត្រចុះបញ្ជីរចនាសម្ព័ន្ធទៅគណៈកម្មការ ស.ក.ប.ទ ។ លំដាប់លំដោយនៃការបង្កើត ស.ក.ប.ទ នឹងបង្ហាញក្នុងទំរង់ 15.2 ។

## 15.4 ថ្លៃសេវាស្រោចស្រព (ISF)

យោងទៅលើនយោបាយសំរាប់និរន្តភាពនៃប្រត្តិបត្តិការ និង ការថែទាំនូវប្រព័ន្ធស្រោចស្រព បន្ទាប់ពីគំរោងត្រូវបានបញ្ចប់ ការទទួលខុសត្រូវនៃប្រត្តិបត្តិការ និង ការថែទាំ ការជួសជុលបន្ទាន់នឹងចូលរួមជាមួយ ស.ក.ប.ទ នៅក្នុងដំណាក់កាលជាបន្តបន្ទាប់ដូចតទៅ :

| **ដំណើរការនៃការប្រមូល ISF បន្តិចម្តងៗ** |
|---|
| ឆ្នាំទី 1 : រដ្ឋាភិបាលចូលរួម 80% និង កសិករដែលជាសមាជិក 20% |
| ឆ្នាំទី 2 : រដ្ឋាភិបាលចូលរួម 60% និង កសិករដែលជាសមាជិក 40% |
| ឆ្នាំទី 3 : រដ្ឋាភិបាលចូលរួម 40% និង កសិករដែលជាសមាជិក 60% |
| ឆ្នាំទី 4 : រដ្ឋាភិបាលចូលរួម 20% និង កសិករដែលជាសមាជិក 80% |
| ឆ្នាំទី 5 : រដ្ឋាភិបាលចូលរួម 0% និង កសិករដែលជាសមាជិក 100% |

ការចំណាយបង្ហាញខាងលើនេះ គឺសំរាប់តែអនុវត្តលើប្រព័ន្ធស្រោចស្រពទាំងអស់ដែលសាងសង់ដោយប្រើប្រាស់ថវិការបស់រាជរដ្ឋាភិបាល ឬ បានមកពីការផ្តល់ពីអន្តរជាតិ និង ស្ថាប័នជាតិ ។ ថ្លៃសេវាប្រើប្រាស់នឹងត្រូវប្រមូលពីបណ្តាអ្នកប្រើប្រាស់ទឹកសំរាប់សេវាស្រោចស្រពដោយគណៈកម្មការ ស.ក.ប.ទ ដែលបានចុះបញ្ជីជាមួយរដ្ឋាភិបាល ។ អត្រារបស់ ISF ត្រូវបានសំរេចដោយ ស.ក.ប.ទ ទៅតាមរូបមន្តខាងក្រោមនេះ ។

$$Y = \frac{X_1 + X_2 + X_3 + X_4 + X_5}{\text{ផ្ទៃដីស្រោចស្រព}} + 20\% \text{ កំនើនទិន្នផល}$$

ដែល Y= ISF / ហ.ត

X1= ការចំណាយលើការថែទាំ និង ជួសជុល

X2= ការចំណាយលើប្រេងឥន្ធនៈក្នុងករណីប្រើម៉ាស៊ីនបូមទឹក

X3= ការចំណាយលើការឧបត្ថម្ភដល់ក្រុមប្រឹក្សាសហគមន៍

X4= ការចំណាយលើការងាររដ្ឋបាល

X5= ការចំណាយលើការងារបំរុង

ចំពោះតំលៃប្រត្តិបត្តិការ និង ការថែទាំអាចប្រែប្រួលពីប្រព័ន្ធមួយនៅប្រព័ន្ធមួយទៀត និង រួមជាមួយ និង ការប្រែប្រួលប្រព័ន្ធក្នុងឆ្នាំនីមួយៗ ព្រមទាំងអាស្រ័យលើការសំរេចរបស់ ស.ក.ប.ទ ផងដែរ ។ 20% នៃកំណើនទិន្នផលនឹងត្រូវថែរក្សាទុកនៅក្នុងគណនីធនាគាររបស់ ស.ក.ប.ទ ដែលថវិកាមួយផ្តល់សំរាប់ការជួសជុលបន្ទាន់ និង ចំណាយលើការថែទាំ ឬ ស.ក.ប.ទ អាចចំណាយក្នុងការធ្វើឱ្យមានលក្ខណៈទំនើបនៃប្រព័ន្ធស្រោចស្រពគឺកែលំអការងារគ្រប់គ្រងទឹកនៅក្នុងកសិដ្ឋាន ។ ការងារនេះត្រូវបន្តសំរាប់រយះពេលប្រាំឆ្នាំដំបូង ដែលអាស្រ័យទៅលើស្ថានភាពថវិកា ស.ក.ប.ទ អាចកាត់បន្ថយភាគរយ ប៉ុន្តែមិនអោយតិចជាង 5% នៃកំណើនផលិតកម្មគណៈកម្មការ ស.ក.ប.ទ ប្រមូល ISF ក្នុងប្រព័ន្ធស្រោចស្រព ហើយនឹងត្រូវ

កត់ត្រាថ្លៃទឹកដែលទទួលពីកសិករ ។ ប្រាក់ចំណូលទាំងអស់ និង ការចំណាយផ្សេងៗដោយ ស.ក.ប.ទ នឹងត្រូវធ្វើការបិទបញ្ជីរៀងរាល់ឆ្នាំ ដោយអ្នកបិទបញ្ជីឯករាជ្យមួយដែលជួយដោយ ស.ក.ប.ទ និង របាយការណ៍ ទាំងអស់ នឹងត្រូវបង្ហាញនៅក្នុងអង្គប្រជុំទូទៅរបស់ FWUC សំរាប់ការសំរេច ។

## 15.5 ការបណ្តុះបណ្តាលដល់ ស.ក.ប.ទ

### 15.5.1 ការផ្ទេរការគ្រប់គ្រងប្រព័ន្ធស្រោចស្រព

ការគ្រប់គ្រងប្រព័ន្ធស្រោចស្រព និង ត្រូវផ្ទេរទៅអោយ ស.ក.ប.ទ តែនៅពេលណាដែលពួកគេមានសមត្ថភាពទទួលការគ្រប់គ្រងទាំងស្រុង ។ ការគ្រប់គ្រងរួមនឹងត្រូវប្រើដើម្បីបង្កើត ចុះបញ្ជីបណ្តុះបណ្តាល និង ពង្រឹង ស.ក.ប.ទ ក្នុងការគ្រប់គ្រង O&M គំរោងរបស់ពួកគេ ។ បន្ទាប់ពីការស្តារឡើងវិញនូវប្រព័ន្ធ ការគ្រប់គ្រងរួមត្រូវបានស្នើដើម្បីប្រព័ន្ធប្រត្តិបត្តិការពេញលេញជាមួយនិងប្រសិទ្ធិភាពយូរអង្វែង ព្រមទាំងពង្រឹងតាមរយៈ ស.ក.ប.ទ ផងដែរ ។ វាត្រូវបានស្នើពីរយៈពេលការគ្រប់គ្រងរួមសំរាប់គំរោងខ្នាតមធ្យម និង គំរោងខ្នាតធំ ។ គំរោងខ្នាតមធ្យម និង គំរោងខ្នាតធំទាំងអស់គឺក្នុងរយះពេលប្រមាណ 4ឆ្នាំ ។ សំរាប់គំរោងខ្នាតជំតូច រយៈពេលនៃការគ្រប់គ្រងរួមគឺពី ពីរទៅបីឆ្នាំ ។ ក្នុងរយៈពេលនៃការគ្រប់គ្រងរួម ស.ក.ប.ទ នឹងត្រូវពង្រឹងដើម្បីអាចកាន់កាប់បន្តការគ្រប់គ្រងទាំងស្រុងនៃប្រតិបត្តិការ និង ការថែទាំ សំរាប់ប្រព័ន្ធនីមួយៗ ក្រសួងធនធានទឹក និង ឧត្តុនិយម សង្ឃឹមទុកក្នុងការអនុវត្តន៍សកម្មភាព ដូចតទៅ ។

- បណ្តុះបណ្តាល ស.ក.ប.ទ និង ក.ក.ប.ទ ទៅលើគឺរិតនៃគំរោងអំពីការតំកល់ឯកសារ សៀវភៅកត់ត្រា គណនេយ្យហិរញ្ញវត្ថុ ការចែកចាយទឹក ការថែទាំប្រព័ន្ធប្រលាយ ចាត់ចែងការប្រជុំ ដោះស្រាយវិវាទ ។ល ។
- រៀបចំនូវផែនការក្បួនថែទាំ
- រៀបចំក្បួនសំរាប់ប្រត្តិបត្តិការ និង ការថែទាំ
- ជំនួយនៅក្នុងការដោះស្រាយវិវាទ
- ជំនួយនៅក្នុងការត្រួតពិនិត្យ និង វាយតំលៃផែនការ ។ តំលៃទាំងអស់សំរាប់ប្រតិបត្តិការ និង ការថែទាំ នឹងត្រូវបែងចែកតាមរូបមន្តដែលបានបង្ហាញពីជំពូកមុន ( ប្រកាស 306 ) ។

### 15.5.2 ការអភិវឌ្ឍន៍ធនធានមនុស្ស

ដើម្បីដើរតួនាទីឱ្យត្រឹមត្រូវ និង ការគ្រប់គ្រងគួរជាទីពេញចិត្តនូវប្រព័ន្ធស្រោចស្រពដែលមានស្រាប់ទាំងអស់ និង ការអភិវឌ្ឍន៍គំរោងទាំងអស់នាពេលអនាគត ពង្រឹង និងបណ្តុះបណ្តាលបុគ្គលិកដែលមានស្រាប់តាមរយៈសិក្ខាសាលាផ្សេងៗដែលនឹងត្រូវធ្វើឡើង និង បុគ្គលិកបន្ថែមដែលបានមកពីការជ្រើសរើស ។ ដើម្បីនឹងផ្ទេរការគ្រប់គ្រងប្រព័ន្ធស្រោចស្រពឱ្យបានល្អទៅដល់ ស.ក.ប.ទ ដែលនឹងត្រូវការសកម្មភាពជាបន្តបន្ទាប់ :

1) ពង្រឹង និង បណ្តុះបណ្តាលបុគ្គលិក ជាពិសេសការទទួលបន្ទុករបស់ ស.ក.ប.ទ និង ការជ្រើសរើសបុគ្គលិកបន្ថែមនៅក្នុងមន្ទីរធនធានទឹក និង ឧត្តុនិយមសំរាប់ចំណុចដូចខាងក្រោម :
    - តំរូវការទឹកក្នុងការដាំដុះ
    - ប្រសិទ្ធិភាពនៃការស្រោចស្រព និង

- វិធីសាស្ត្រអនុវត្តក្នុងការស្រោចស្រព

2) ការធ្វើសិក្ខាសាលាបណ្តុះបណ្តាលនៅថ្នាក់ខេត្ត

3) បណ្តុះបណ្តាល និង ពង្រឹង ស.ក.ប.ទ ក្នុងកិច្ចសហការជាមួយក្រសួងធនធានទឹក និង ឧត្តុនិយម

4) ផ្តល់នូវបច្ចេកទេសទៅដល់ ស.ក.ប.ទ ក្នុងកិច្ចសហការជាមួយ ក្រសួងធនធានទឹក និង ឧត្តុនិយម

5) បណ្តុះបណ្តាលការត្រួតពិនិត្យ និង វាយតំលៃនៅថ្នាក់មជ្ឈិម និងថ្នាក់ខេត្ត

### 15.5.3 ការបណ្តុះបណ្តាល ក.ក.ប.ទ និង ស.ក.ប.ទ

អ្នកតំណាងរបស់ ក.ក.ប.ទ និង ស.ក.ប.ទ នឹងត្រូវបានបណ្តុះបណ្តាលសមត្ថភាពក្នុងការអនុវត្តន៍គ្រប់គ្រងប្រព័ន្ធក្នុងការសហការជាមួយក្រសួងធនធានទឹក និង ឧត្តុនិយម ។ មុខវិជ្ជាសំខាន់ៗសំរាប់ការបណ្តុះបណ្តាលគឺ :

1) តួនាទី និង ការងាររបស់សមាជិកក្រុមប្រឹក្សា ស.ក.ប.ទ និង អ្នកតំណាង ក.ក.ប.ទ ជាពិសេសគឺការងារ

- ការងាររដ្ឋបាល និង ការតំកល់ឯកសារ
- គំរោងផែនការ
- ប្រតិបត្តិការ និង ការថែទាំប្រព័ន្ធប្រើប្រាស់ម៉ាស៊ីន ប្រលាយ និង ម៉ាស៊ីនបូមទឹក (ក្នុងករណីមានបូមទឹក)
- ការប្រមូលថ្លៃសេវាប្រើប្រាស់ទឹក

2) ផែនការប្រតិបត្តិការ និង ការថែទាំ

3) ការគ្រប់គ្រងទឹកនៅលើដីកសិដ្ឋាន

4) ការរៀបចំថវិកា និង គ្រប់គ្រងថវិកាថ្លៃសេវាប្រើប្រាស់ទឹក

### 15.5.4 ការបណ្តុះបណ្តាលនៅស្រែ

ប្រព័ន្ធស្រោចស្រពត្រូវការនូវការថែទាំយ៉ាងល្អសំរាប់ការចែកចាយទឹកត្រឹមត្រូវទៅស្រែ ។ ស្មៅដែលដុះ និង ល្បប់ដែលនៅក្នុងប្រឡាយ និង ការហូរច្រោះច្រាំងនឹងធ្វើអោយប្រព័ន្ធចុះថយប្រសិទ្ធិភាពស្រោចស្រព ។ ដូច្នោះអ្នកប្រតិបត្តិការប្រព័ន្ធ និង អ្នកសំអាតស្លាមភ្លោះ (ក្នុងករណីដែលជារបស់ ក.ក.ប.ទ) ត្រូវការបណ្តុះបណ្តាលពីប្រតិបត្តិការលើសំណង់ស្រោចស្រព និង ការងារប្រចាំថ្ងៃ និង រយៈពេលថែទាំប្រឡាយ និង សំខាន់ដើម្បីធ្វើឱ្យប្រព័ន្ធដំណើរការតាមសមត្ថភាព ដែលបានរៀបចំដូចមានបង្ហាញចំណុចសំខាន់ៗដូចខាងក្រោម :

1) គំរោងប្រតិបត្តិការ

- ការតំឡើងឧបករណ៍បង្វែរនៅទ្វារទឹក និង កត់ត្រាកំពស់ទឹក
- ការបើក/បិទទ្វារទឹក និង កត់ត្រាកំពស់ទឹក
- ពិនិត្យមើលការចែកចាយទឹក

- ជៀសវាងពីការប្រើប្រាស់ទឹកខុសច្បាប់
- ត្រួតពិនិត្យខ្នងទំនប់

2) គំរោងការថែទាំ

- ប្រមូលល្បប់ចេញពីប្រឡាយ
- ដាំស្មៅលើទំនប់ការពារ និង
- ជួសជុលទ្វារទឹក និង ដាក់ខ្លាញ់រហាត់

3) ការជួសជុលបន្ទាន់

- កន្លែងស្រុតនៃខ្នងទំនប់
- ការចាក់ដីបង្ហាប់ និង ដាំស្មៅ និង
- ការសាងសង់ឡើងវិញនូវសំណង់ដែលខូចខាត ។

ជាគោលការណ៍ បុគ្គលិកនៅការដ្ឋានត្រូវការនូវការបណ្ដុះបណ្ដាលពីការកំណត់តំរូវការស្រោចស្រពពិតប្រាកដ និង វិធីសាស្ត្រផ្តល់ទឹក និង ការវាស់ចំណុះទឹកស្រោចស្រពដែលបានប្រើប្រាស់ ។ សកម្មភាពទាំងអស់នេះនឹងត្រូវការសំរាប់វាយតំលៃប្រសិទ្ធិភាពស្រោចស្រព ។ កសិករក៏ត្រូវការនូវការបណ្ដុះបណ្ដាលពីវិធីសាស្ត្រអនុវត្តន៍ទឹកខុសៗគ្នា ដើម្បីកែលំអការគ្រប់គ្រងទឹកនៅស្រែដើម្បីឱ្យបង្កើនប្រសិទ្ធិភាពស្រោចស្រព ជាពិសេសនៅ ពេលខ្វះខាតទឹក ។

# ជំពូក 16 ការប្រតិបត្តិ និង ការថែទាំ

## 16.1. ការប្រតិបត្តិ

### 16.1.1 ការរៀបចំតារាងពេលនៃការស្រោចស្រព

#### (1) គោលការណ៍ប្រតិបត្តិ

ដោយពិចារណាទៅលើកំរិតធនធានទឹក ហើយថែមទាំងការចែកចាយរបស់វានោះ គោលការណ៍នៃការប្រតិបត្តិខាងក្រោមត្រូវបានដាក់ស្នើឡើង :

1) វិធីស្រោចស្រពដោយសន្សំសំចៃទឹកនឹងត្រូវបានអនុវត្ត ។

2) ការបង្ហូរទឹក ប្រលាយមេ និង ប្រលាយរងត្រូវបានប្រតិបត្តិបន្តបន្ទាប់រយៈពេល 24 ម៉ោង ។

2) ប្រលាយបញ្ចូលស្រែ និង ផ្លូវទឹកហូរនឹងត្រូវបានប្រតិបត្តិបន្តបន្ទាប់សំរាប់រដូវវស្សា ប៉ុន្តែការស្រោចស្រពវិល នឹងត្រូវបានអនុវត្តក្នុងអំឡុងពេលរដូវប្រាំង ឬ រយៈពេលរាំងស្ងួត ក្នុងនោះប្រព័ន្ធស្រោចស្រពមិនអាចធ្វើអោយសមស្របនៃតំរូវការទាំងអស់បានទេ ។

3) ផ្ទៃដីដែលអាចស្រោចស្រពនៅរដូវប្រាំងនឹងត្រូវតិចជាងផ្ទៃដីរដូវវស្សា ។ ទឹកស្រោចស្រពនឹងត្រូវបានចែកចាយដោយស្មើគ្នាទៅប្លុកចែកចាយនីមួយៗ ហើយការពិភាក្សាគួរត្រូវបានធ្វើដោយប្លុកចែកចាយពីរបៀបដើម្បីប្រើប្រាស់ទឹក ដែលមានកំនត់សំរាប់ផ្ទៃដីស្រោចស្រព ។

#### (2) ការរៀបចំតារាងពេលការផ្គត់ផ្គង់ទឹក

តារាងពេលផ្គត់ផ្គង់ទឹក (WSS) នឹងត្រូវបានកំនត់រាល់ឆ្នាំមុនពេលចាប់ផ្តើមដាំដុះ ។ មុននឹងការវាយតំលៃនៃតំរូវការទឹក ដោយការពិភាក្សាទៅលើគំរូនៃការដាំដុះ គួរតែត្រូវបានធ្វើឡើង ។ សមាជិកនៃគណៈកម្មាធិការនៃសហគមន៍កសិករប្រើប្រាស់ទឹក (FWUC) ទទួលខុសត្រូវនៃតារាងពេលផ្គត់ផ្គង់ទឹកនឹងពិគ្រោះយោបល់ជាមួយ MOWRAM (DWRAM) ចំពោះឯកត្តាតំរូវការទឹកស្រោចស្រពនៃឆ្នាំ ប្រចាំកន្លះខែជាមូលដ្ឋាន ។ ពេលនោះដោយយោងទៅលើឯកត្តាតំរូវការទឹកស្រោចស្រព ។ តារាងពេលស្រោចស្រពទៅប្លុកចែកចាយនីមួយៗ (តារាងពេលវិល) នឹងត្រូវបានកំនត់ដោយសហគមន៍កសិករប្រើប្រាស់ទឹក (FWUC) នៅកំរិតទីពីរ ។

#### (3) ការផ្សព្វផ្សាយជំនឹង និង ការផ្សាយជាសាធារណៈនៃតារាងពេល

សារៈសំខាន់នៃការផ្សព្វផ្សាយដំនឹង និង ការផ្សាយជាសាធារណៈដ៏ធំទូលាយនៃតារាងពេលផ្គត់ផ្គង់ទឹកក្នុងចំណោមកសិករអោយបានយ៉ាងគ្រប់គ្រាន់ជាមុននៃការចាប់ផ្តើមនៃរដូវដាំដំណាំ ចាំបាច់ត្រូវការគូសបញ្ជាក់ដ៏ខ្លាំង ។ ហេតុដូច្នេះវាមានសារៈសំខាន់ដែលតារាងពេលផ្គត់ផ្គង់ទឹក ត្រូវបានរៀបចំជាម៉ោងពេលហើយត្រូវ

ផ្តល់អោយដល់កសិករ ដូច្នេះពួកគាត់អាចមានផែនការទៅតាមដំណាំរបស់គាត់ ។ ការរៀបចំនៃការផ្គត់ផ្គង់ទឹក និង ធារទឹកនៃការប្រតិបត្តិត្រូវបានបង្ហាញក្នុង រូបភាព 16.1 ។

### 16.1.2 ការប្រតិបត្តិសំណង់

#### (1) ការប្រតិបត្តិប្រព័ន្ធបង្ហៀរទឹក

គោលការណ៍សំរាប់ច្បាប់ប្រតិបត្តិនៃប្រព័ន្ធអាងទឹកត្រូវបានរាយដូចខាងក្រោម:

1) ការប្រតិបត្តិសំរាប់អាងទឹក គួរតែមានភាពងាយស្រួល

2) ទ្វារទឹកចូលនៃការបង្ហៀរទឹក ឬ ប្រលាយមេ គួរតែត្រូវបានប្រតិបត្តិដើម្បីអោយធារទឹកដែលត្រូវបង្ហៀរមិនលើសចំណុះប្រលាយដែលគ្រោង ។

3) ក្នុងអំឡុងពេលដែលអាងទឹកមានទឹកពេញ ហើយទឹកដែលលើសនោះហូរពីលើទំនប់បង្ហៀរ ទ្វារទឹកដែលត្រួតពិនិត្យធារទឹកហូរចូលអាង (បើមាន) គួរតែត្រូវបានបិទ ។

4) ការទាក់ទងនៃការបិទ គួរតែត្រូវបានរក្សារវាងអ្នកថែរក្សាទ្វារទឹកនៃអាងទឹក និង អ្នកប្រើប្រាស់ទឹកក្នុងតំបន់ស្រោចស្រព ជាពិសេសនៅពេលមានព្យុះខ្លាំង និង ពេលរាំងស្ងួត ។

#### (2) ការប្រតិបត្តិប្រព័ន្ធប្រលាយសំរាប់ការផ្គត់ផ្គង់ទឹក និង ការចែកចាយ

ប្រព័ន្ធប្រលាយស្រោចស្រព ជាទូទៅមានប្រលាយមេមួយ ប្រលាយរង និង ប្រលាយចែកចាយមួយចំនួន ។ ប្រលាយមេមានប្រភពមកពី អាង រឺ សំណង់បង្ហៀរទឹកទន្លេ ។ ប្រលាយរងមានសាខាចេញពីប្រលាយមេ និង ប្រលាយរងនីមួយៗស្រោចស្រពពី 10 ទៅ 30 ប្លុកចែកចាយ ។ រាល់ប្លុកចែកចាយត្រូវបានបំរើដោយប្រលាយចែកចាយតាមលំដាប់លំដោយ ។

គោលការណ៍ និង ច្បាប់ប្រើប្រាស់គ្រឹះសំរាប់ការផ្គត់ផ្គង់ទឹកស្រោចស្រពត្រូវបានផ្តល់នូវយោបល់ដូចខាងក្រោម:

1) ច្បាប់ប្រតិបត្តិសំរាប់ការផ្គត់ផ្គង់ទឹកគួរតែមានភាពងាយស្រួល

2) កត្តាកំរិតទឹកភ្លៀងមិនត្រូវបានយកមកគិត សំរាប់ការប្រតិបត្តិនៃការផ្គត់ផ្គង់ទឹកស្រោចស្រព ក្នុងគោលការណ៍នេះទេ ។ កំរិតទឹកភ្លៀងមានភាពមិនទៀងទាត់យ៉ាងខ្លាំង ហើយដូច្នេះការផ្គត់ផ្គង់ទឹកពឹងផ្អែកលើចំនួនទឹកភ្លៀង គឺមិនអាចអនុវត្តបានឡើយ ។

3) ច្បាប់ប្រតិបត្តិនឹងត្រូវពឹងផ្អែកលើតំរូវការទឹកស្រោចស្រព ដែលបានប៉ាន់ស្មាននៅរយៈពេលកើតមានឡើងវិញ 5ឆ្នាំ (80% ភាពទុកចិត្តបាន) ។

4) ការប្រតិបត្តិនឹងត្រូវអនុវត្តប្រចាំកន្លះខែជាមូលដ្ឋានក្នុងប្រព័ន្ធប្រលាយស្រោចស្រព ។

5) មានតែចំណុះទឹកស្តុករបស់អាងជាក់ស្តែងតែប៉ុណ្ណោះ គួរតែត្រូវបានយកមកគិត សំរាប់ការផ្គត់ផ្គង់ទឹកស្រោចស្រពពីសំណង់បង្ហៀរទឹក ។ ច្បាប់ប្រើប្រាស់ខាងក្រោមបានស្នើឡើង សំរាប់អាងក្តបត្របែកនៃគំរោងផ្នែកខាងលើស្ទឹងស្លាគូ (USP) បង្ហាញគំរូលនៃការប្រើប្រាស់អាងទឹកនេះ ។ ការប្រតិបត្តិ

ត្រូវបានអភិវឌ្ឍន៍ក្នុងការពិចារណាលើការកាត់បន្ថយនៃការខ្វះខាតទឹកស្រោចស្រពនៅពេលរាំងស្ងួត ព្រមទាំង បង្កើនការផ្គត់ផ្គង់ទឹកនៅរដូវវស្សាបានខ្ពស់ ។




តំរូវការទឹកស្រោចស្រព (SIW)

ឯកតា :ម³/វិនាទី

| ឧសភា | | មិថុនា | | កក្កដា | | សីហា | | កញ្ញា | | តុលា | | វិច្ឆិកា | | ធ្នូ | | មករា | | កុម្ភៈ | | មីនា | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 1 | 2 | 1 | 2 | 1 | 2 | 1 | 2 | 1 | 2 | 1 | 2 | 1 | 2 | 1 | 2 | 1 | 2 | 1 | 2 | 1 | 2 |
| 0.00 | 0.11 | 0.22 | 0.31 | 0.33 | 1.41 | 1.71 | 1.89 | 3.06 | 3.28 | 1.99 | 2.27 | 3.39 | 2.36 | 1.36 | 0.70 | 0.38 | 0.44 | 0.54 | 0.41 | 0.30 | 0.12 |

ឧទាហរណ៍ ការចាប់ផ្តើមលើកដំបូងកន្លះខែសីហា ការស្តុកទឹកជាក់ស្តែងគឺច្រើនជាងចំនុះស្តុករបស់អាង (ទឹកហៀរចេញតាមរយៈទំនប់បង្ហៀររបស់អាង) 1.71ម³/វិ x 1.2ដង = 2.05ម³/វិ នឹងត្រូវបានបញ្ចេញទៅប្រលាយមេ ។ ក្នុងករណីដែលស្តុកតិចជាង 1.5 MCM 1.71ម³/វិ x 0.7 = 1.20ម³/វិ គួរតែបានបញ្ចេញ ។

ក្នុងអំឡុងពេលទឹកជំនន់ក្នុងវាលស្រែស្ទើរតែទាំងអស់ សំណង់ទ្វារទឹកចូលនៃប្រលាយមេ គួរតែត្រូវបិទ ។

ច្បាប់នេះគួរតែត្រូវបានពិនិត្យមើលឡើងវិញ និង ផ្លាស់ប្តូរលើមូលដ្ឋានដែលប្រាកដនិយម នូវអំឡុងពេលចាំបាច់ណាមួយនៃដំណាក់កាលប្រើប្រាស់ជាក់ស្តែង ។

6) រដូវស្រោចស្រពត្រូវបានបែងចែកជាបីរដូវ ដោយយោលទៅតាមគំរូនៃការដាំដុះ រឺ តំរូវការទឹកស្រោចស្រព ។ រដូវទី 1គឺ 2ខែ ពីខែឧសភាដល់ខែកក្កដា ពេលចំការត្រូវបានដាំ ។ នៅក្នុងរដូវនេះតំរូវការទឹកស្រោចស្រពមានចំនួនតិច គឺស្ថិតនៅចន្លោះពី 0.11ម³/វិ ទៅ 0.33 ម³/វិ ។ ពាក់កណ្តាលរដូវ គឺរយៈពេលពីចុងខែកក្កដាដល់ចុងខែធ្នូពេលដែលស្រូវត្រូវស្ងួត ។ តំរូវការទឹកស្រោចស្រព គឺច្រើនជាងគេបំផុតក្នុងរដូវនេះ បន្ទាប់មករដូវទី 3 គឺរយៈពេល ពីខែមករា ដល់ខែមិនាពេលដែលដំណាំចំការត្រូវបានដាំ ។ តំរូវការទឹកស្រោចស្រពក្នុងរដូវនេះស្ថិត ចន្លោះ ពី 0.12ម³/វិ ទៅ 0.54ម³/វិ ។

ប្រលាយមេ និង ប្រលាយរងនឹងត្រូវប្រើប្រាស់ 24 ម៉ោងបន្តបន្ទាប់គ្នាក្នុងការនាំទឹកពេញមួយរដូវ

ស្រោចស្រព ។ នៅក្នុងរដូវទី 1 និងទី 3នេះពេលដែលតំរូវការទឹក គឺតិចបំផុតត្រូវត្រួតពិនិត្យទ្វារទឹកលើប្រលាយមេ និង/ឬ ប្រលាយរងនឹងត្រូវបានបិទទាំងស្រុង និង ផ្នែកហូរពីចំហៀងបានផ្តល់ដោយសំណង់ត្រួតពិនិត្យកំពស់ទឹក នឹងត្រូវបានប្រើប្រាស់សំរាប់ការនាំទឹក ។

7) ប្រលាយចែកចាយនឹងត្រូវប្រតិបត្តិ ដើម្បីនឹងផ្គត់ផ្គង់ទឹកលើមូលដ្ឋាននៃការនាំទឹក 24 ម៉ោង បន្តបន្ទាប់គ្នាក្នុងអំឡុងពេលកណ្តាលរដូវ លើកលែងតែប្រលាយចែកចាយតូចៗ ដែលមានផ្ទៃដីស្រោចស្រពតិចជាង 30ហ.ត ។ សំរាប់កំឡុងពេលរដូវទី 1និង ទី3 ការផ្គត់ផ្គង់ទឹកវិល នឹងត្រូវអនុវត្តក្នុងចំណោមប្រលាយចែកចាយទាំងអស់ក្នុងប្រលាយរងនីមួយៗ ។ ប្រលាយចែកចាយតូចៗនឹងត្រូវបានផ្គត់ផ្គង់ទឹកដោយយោងតាមតារាងពេល ផ្គត់ផ្គង់វិលក្នុងចំណោមប្រលាយតូចៗ សូម្បីតែក្នុងកណ្តាលរដូវក៏ដោយ ។

### (3) ការប្រតិបត្តិសំរាប់វិធីស្រោចស្រពដោយសន្សំសំចៃទឹក

ដើម្បីថែរក្សាប្រសិទ្ធិភាពអនុវត្តការស្រោចស្រពខ្ពស់ ទឹកស្រោចស្រពទៅវាលស្រែ គួរតែត្រូវចែកចាយនៅធារទឹកច្រើនណាស់ ។ ដោយគិតថាទឹកស្រោចស្រពត្រូវចែកចាយពីប្រលាយចែកចាយ ឬ ផ្លូវទឹកហូរទៅស្រែ និង ពីស្រែមួយទៅស្រែមួយ ធារទឹកពី 0 l/វិ ទៅ20 l/វិ គឺជាសេចក្តីត្រូវការ ។ ដោយធារទឹកនេះការផ្គត់ផ្គង់ទឹកសំរាប់ការរៀបចំដីស្រែ1 ហ.តប្រើពេលកន្លះថ្ងៃទៅមួយថ្ងៃ ។ អំឡុងពេលធម្មតានៃរដូវស្រោចស្រពខ្ពស់បំផុត វាលស្រែ 10ទៅ20ហ.តអាចត្រូវបានស្រោចស្រពរៀងរាល់ថ្ងៃ ។ ការងាររាស់ និង ស្ទូងគួរតែត្រូវអនុវត្តជាបន្ទាន់ក្រោយពេលស្រែមួយៗមានទឹកពេញ ។

ក្នុងវិធីស្រោចស្រពសន្សំសំចៃទឹកទឹក ដែលទាក់ទងទៅនឹងចំនួនទឹកភ្លៀងបានការ ដែលយកចេញពីការប្រើប្រាស់ទឹក ត្រូវបានផ្គត់ផ្គង់ក្នុងអំឡុងរយៈពេលក្រោយការស្ទូង រហូតដល់ចប់ការកាប់គាស់ ភ្ជួរ រាស់ និងពេលបង្កើតទិន្នផល ។ ក្នុងវិធីនេះទឹកដែលនៅក្នុងស្រែហូរចេញបន្តិចម្តងៗ ហើយក្រោយមកផ្ទៃដីបានស្ងួតបន្តិចម្តងៗ ពីព្រោះគ្មានទឹកដែលទាក់ទងទៅនឹងការបាត់បង់ដោយជំរាប ដែលត្រូវបានផ្តល់អោយវាទេ ។ ក្នុងស្ថានភាពបែបនេះ ប្រសិនបើទឹកត្រូវផ្គត់ផ្គង់ក្នុងបរិមាណទឹកតិច ចំនួនទឹកភាគច្រើនត្រូវបានខ្ជះខ្ជាយឥតប្រយោជន៏ និង ទឹកមិនបាននាំបានចំងាយឆ្ងាយទេ ។ ទឹកគួរតែត្រូវផ្តល់ឱយបានបរិមាណច្រើនល្មម ថ្វីបើគ្មានទឹកសល់ក្នុងស្រែក៏ដោយ ។ វាលស្រែនីមួយៗ គួរតែត្រូវផ្តល់តាមផ្លូវទឹកហូរដើម្បីនឹងនាំទឹកអោយបានល្អទៅស្រែផ្នែកខាងក្រោមផងដែរ ។ វាគឺជាបំណងដើម្បីរក្សាទឹកដែលមានក្នុងដីក្នុងជំរៅឫសដំណាំមិនតិចជាង 75% នៃសំណើមជោគជាំទាំងស្រុង ដើម្បីថែរក្សាទិន្នផលស្រូវអោយបានល្អ ។ ដើម្បីសំរេចតំរូវការនេះនៅក៏រិតពិតប្រាកដមួយ ការអនុវត្តន៏ការស្រោចស្រពគួរតែត្រូវបានធ្វើមួយសប្តាហ៏ម្តង ។

អំឡុងរយៈពេល 30 ថ្ងៃនៃការចាប់ផ្តើមនៅដើមដំបូងរហូតដល់ចប់ការចេញផ្កា ដែលជារយៈពេលងាយខូចខាតច្រើន ទល់នឹងការខ្វះខាតទឹក ទឹកដែលបន្ថែម គួរតែត្រូវផ្គត់ផ្គង់ដើម្បីនឹងរក្សាអោយលិចល្មម ។

## 16.2 ការថែទាំ

### 16.2.1 ការទទួលខុសត្រូវ

ការថែទាំឧបករណ៍សំណង់ធារាសាស្ត្រនឹងត្រូវបានធ្វើយ៉ាងច្រើនដោយ FWUC ក្រោយពីការងារសាងសង់ចប់រួចរាល់ និង ការគ្រប់គ្រងសំណង់ទាំងនោះ ។ FWUC នឹងត្រូវរៀបចំមុនការចាប់ផ្តើមការងារសាងសង់ដូចដែលបាននិយាយក្នុងជំពូក 15 ហើយ MOWRAM និង ការិយាល័យរដ្ឋាភិបាលដែលពាក់ព័ន្ធដទៃទៀតគួរជ្រោមជ្រែង FWUC នៅឆ្នាំពិតប្រាកដក្រោយពេលបញ្ចប់ការសាងសង់រួចរាល់ ដើម្បីដឹងច្បាស់លាស់ពីប្រតិបត្តិការ និង ការថែទាំ (O&M) ដោយ FWUC ហើយនឹងការទ្រទ្រង់របស់គំរោង ។ ទំហំ FWUC ផ្អែកលើខ្នាតនៃគំរោង ។ ប្រភេទជាច្រើននៃ FWUCs ដែលអនុលោមទៅតាមការរៀបចំ FWUC ដែលបានលើកឡើងក្នុងជំពូក 15 ត្រូវបានសន្មត់ដូចដែលបានបង្ហាញក្នុងរូបភាព 16.2 ។ FWUC នីមួយៗគួរតែមានគណៈកម្មាការ FWUC ដែលនឹងដើរតួនាទីយ៉ាងច្រើននៃប្រតិបត្តិការ និង ការថែទាំ (O&M) ។

ការថែទាំសំណង់ធារាសាស្ត្រនឹងត្រូវមានផែនការដោយ FWUC ផ្ទាល់ ។ ដំណើរការថែទាំសំណង់ធារាសាស្ត្រ ត្រូវបានពិពណ៌នាលំអិតក្នុងអនុផ្នែកខាងក្រោម និង បានសង្ខេបក្នុងតារាង 16.1 ។

### 16.2.2 ការថែទាំគំរោងស្រោចស្រពខ្នាតធំ/មធ្យម

#### (1) ប្រភេទនៃការថែទាំ

ការងារថែទាំនឹងត្រូវបានរៀបចំឡើងជា 4 ប្រភេទ អាងទឹកប្រឡាយបង្ហៀទឹក និង ប្រឡាយមេ ប្រឡាយរង និង ប្រឡាយតាមវាលស្រែ ( ប្រលាយចែកចាយ និង ផ្លូវទឹកហូរ) ។ ភាពញឹកញាប់ និង ទំហំនៃការងារថែទាំគឺ 1) ការត្រួតពិនិត្យ និង ថែទាំជាប្រចាំ (រៀងរាល់ថ្ងៃទៅមួយសប្តាហ៍ម្តងតាមតំរូវការ) 2) ការត្រួតពិនិត្យរយៈពេល និង ការជួសជុល ( មួយឆ្នាំម្តងមុនរដូវវស្សា) និង 3) ដែលជារយៈពេលនៃការស្តារឡើងវិញ (5ឆ្នាំម្តង) ។ កំលាំងពលកម្មដែលចាំបាច់សំរាប់ការថែទាំជាប្រចាំ និង រយៈពេលជួសជុលនឹងត្រូវបានផ្តល់ដោយ FWUC ជាការបង់វិភាគទាន នៅពេលដែលជារយៈពេលនៃការកែលំអឡើងវិញ ដែលត្រូវការទំហំការងារធំជាង សមាជិកក្រុមគ្រួសារកសិករប្រើប្រាស់ទឹក (FWUC) នឹងត្រូវជួសជុលជាកំលាំងពលកម្មលើផ្អែកមូលដ្ឋាននៃការងារ ។

#### (2) ការថែទាំអាងទឹក

សមាជិកគណៈកម្មការ FWUC ទទួលបន្ទុកអាងទឹក ឬ ប្រព័ន្ធមេនឹងប្រកាន់យកភាពទទួលខុសត្រូវនៃការគ្រប់គ្រង និង ថែទាំអាងទឹក ។ មនុស្សដែលទទួលបន្ទុកប្រតិបត្តិសំណង់ទ្វារទឹកចូល និង ថែទាំទ្វារទឹករបស់អាងទឹកទៅតាមផែនការប្រតិបត្តិ និង ការថែទាំដែលបានរៀបចំដោយ FWUC រៀងរាល់ឆ្នាំគាត់នឹងត្រួតពិនិត្យផងដែរទៅលើការខូចខាតទ្វារទឹក កំទេចកំទីដែលមានការជ្រាបទឹក បន្ទាប់មករក្សាទុកបញ្ជីត្រួតពិនិត្យ និង ថែរក្សាដែលនឹងត្រូវរាយការណ៍ និង ពន្យល់ដល់គណៈកម្មការ FWUC យូៗម្តងជាផ្អែកនៃការ

ត្រួតពិនិត្យ និង ថែរក្សាជាប្រចាំ ។ ចំនែកឯរយៈពេលនៃការត្រួតពិនិត្យ និង ជួសជុលការគូសបញ្ជាក់នៃមុខងារទ្វារទឹក ការលាបថ្នាំការពារច្រេះ ការយកចេញកំទេចកំទី ការងារជួសជុលបន្តិចបន្តួចទំនប់ និង សំណង់ធារាសាស្ត្រផ្សេងទៀតដោយកំលាំងមនុស្សនឹងត្រូវបានអនុវត្តឡើង ។ រយៈពេលនៃការស្តារឡើងវិញគួរទាក់ទងនឹងការងារជួសជុលទំនប់ និង សំណង់ធារាសាស្ត្រដែលពាក់ព័ន្ធការយកចេញកករដីមុខទ្វារទឹកចូល និង ការថែទាំទ្វារទឹកដើម្បីអោយចរន្តទឹកហូរទៅទ្វារទឹកបានយ៉ាងងាយស្រួល ។

## (3). ប្រឡាយមេ និង ប្រឡាយបង្ហូរទឹក

ការថែទាំប្រលាយបង្ហូរទឹកបានត្រូវអនុវត្តដោយសមាជិកគណៈកម្មការ FWUC ដែលទទួលបន្ទុកលើប្រលាយមេ ។ ក្នុងករណីដែលបញ្ហាដូចជាការខូចខាតលើសំណង់ ការរាំងស្ទះនៃផ្នែកប្រលាយ ការដក និង បង្ហូរដោយខុសច្បាប់ត្រូវអះអាងបញ្ជាក់ គាត់គួរតែរក្សាទុកបញ្ជី និង រាយការណ៍ទៅគណៈកម្មការ FWUC កោះហៅមកធ្វើការប្រជុំ និង ដោះស្រាយបញ្ហាទាំងនោះ ។ ចំណែកឯរយៈពេលនៃការត្រួតពិនិត្យ និង ជួសជុលការត្រួតពិនិត្យ និង ការជួសជុលនៃសំណង់បញ្ចូលទឹក សំណង់ឆ្លងកាត់ ដូចជាការយកចេញកករ ការលាបថ្នាំទ្វារទឹក ការជួសជុលប្រលាយដោយដៃគួរត្រូវបានធ្វើ ។

រយៈពេលនៃការស្តារឡើងវិញ គួរបញ្ចូលការស្តារឡើងវិញទំនប់ និង ការត្រួតពិនិត្យផ្លូវថ្នល់ ការយកចេញកករដី និង កំទេចកំទីពីក្នុងប្រលាយ និង ការងារជួសជុលធំនៃសំណង់ ។ តំលៃចាំបាច់គួរតែត្រូវបង្កើតដោយផ្នែកថ្លៃសេវាស្រោចស្រព (ISF) ។




រូបភាព ការថែទាំប្រឡាយមេ

ការងារប្រចាំ និង រយៈពេលត្រួតពិនិត្យ និង ការថែទាំប្រលាយមេ គួរត្រូវបានអនុវត្តដោយសមាជិក FWUG នៃប្លុកចែកចាយដែលភាគច្រើនផ្នែកខាងលើនៃប្រលាយរង សំរាប់ផ្នែកមួយរវាងសំណង់បង្ហូរទឹករបស់វា (ចំនុចចាប់ផ្តើមនៃប្រលាយរង) និង សំណង់បង្ហូរទឹកផ្នែកខាងលើ ដូចបានបង្ហាញនៅខាងស្តាំ ។ សំណង់ដែលត្រួតពិនិត្យ និង ការថែរក្សាគួរស្រដៀងនឹងប្រលាយបង្ហូរទឹកទាំងនោះ ។

## (4) ប្រឡាយរង

ការត្រួតពិនិត្យ និង ជួសជុលសំរាប់រយៈពេលថែទាំជាប្រចាំ គួរអនុវត្តដោយកំលាំងមនុស្ស ។ ការត្រួតពិនិត្យ និង ជួសជុសជាប្រចាំគួរអនុវត្តជាគោលដោយ FWUG ប៉ុន្តែការងារជាក់ស្តែង ដូចជាការកាត់ស្មៅ និង/ឬ ការយកកករដីចេញនឹងត្រូវអនុវត្តដោយសមាជិក FWUG ដែលនៅជិតប្រលាយ ។

សមាជិក FWUG នៃប្លុកចែកចាយគួរទទួលខុសត្រូវសំរាប់ការងារថែទាំរាំងសំណង់បញ្ចេញទឹក និង សំណង់ បញ្ចេញទឹកផ្នែកខាងលើ ដូចបានបង្ហាញនៅខាងស្តាំ ។ ការជួសជុលការខូចខាត តិចតួចលើប្រលាយរង ដែលបានប៉ះពាល់ដល់ប្លុកប្រលាយចែកចាយនឹងត្រូវបានត្រូវជួសជុសយ៉ាងសមរម្យតាមរយៈពេលនៃការងារជួសជុល ។ ការងារទាំងនេះគួរតែត្រូវបានរៀបចំយ៉ាងច្រើនដោយ FWUGs សំរាប់ការងារជួសជុល ប្លុកចែកចាយទាំងអស់បញ្ហាដោយប្រលាយរង គួរផ្តល់កំលាំងពលកម្ម និង សំភារៈហើយ




រូបភាព ការថែទាំប្រឡាយរង

និង ឧបករណ៍ចាំបាច់បានត្រូវយកមកអោយដោយ FWUGs ដោយការប្រើផ្នែក ISF រយៈពេលនៃការស្តារឡើងវិញ (រៀងរាល់ 5ឆ្នាំ) បានត្រូវអនុវត្តសំរាប់ការជួសជុលធំប្រលាយ និង សំណង់ លើផ្នែកការងារជាមូលដ្ឋានដោយការប្រើ ISF បញ្ជាស់ ។

### (5) ប្រលាយចែកចាយ និង ផ្លូវទឹក

ការងារថែទាំប្រឡាយចែកចាយ និង ផ្លូវទឹកបានត្រូវអនុវត្តឡើងដោយអ្នកចាត់ចែងកសិករ (FO) ដែលមានតួនាទីដូចចែងក្នុងអនុផ្នែក 15.3.3 "ការបង្កើត FWUC" ។ ការត្រួតពិនិត្យជាប្រចាំធ្វើដោយ FOs និង ការងារថែទាំធ្វើដោយសមាជិក FWUG ។ រយៈពេលជួសជុល គួរត្រូវធ្វើមុនរដូវវស្សាដែលចំណាយពេលប្រហែល 10 ថ្ងៃ ដោយសមាជិកទាំងអស់ ។ ការងារសំខាន់នឹងមានការយកកករដីចេញ ការលាបថ្នាំទ្វារទឹក ។ល។ និង សំភារៈ ឬ តំលៃសំរាប់ទិញសំភារៈទាំងនោះ បានត្រូវទារដោយ FOs ទៅ FWUC ។

## 16.2.3 ការថែទាំគំរោងស្រោចស្រពខ្នាតតូច ឬ តូចបំផុត

ការប្រតិបត្តិ និង ថែទាំអាងទឹកតូចៗគួរត្រូវបានធ្វើដោយក្រុមកសិករប្រើប្រាស់ទឹក (FWUC) ។ ជំរៅទឹកនៃអាងជាទូទៅ គឺរាក់ហើយនិងអាចមានការផ្លាស់ឥទ្ធិពលនៃកករដី ។ ទោះបីជាយ៉ាងណាក៏គ្មានសំណង់ពាក់ព័ន្ធពិសេសសំរាប់ការបង្ហូរកករដីចេញត្រូវបានគេគិតទេ ការយកកករដីចេញជុំវិញសំណង់បញ្ចូលទឹក គួរត្រូវធ្វើយូរៗម្តង ។ ចំណែកឯទំនប់ការត្រួតពិនិត្យ និង ការថែទាំជាប្រចាំ គួរត្រូវធ្វើនៅលើការហូរច្រោះនៃជើងទេដោយរលក និង ទឹកភ្លៀង ។ សំភារៈដែលការពារច្រេះ គួរត្រូវលាបថ្នាំរៀងរាល់ឆ្នាំ និង ការយកចេញនូវកករដីក្នុងបំពង់លូ គួរតែត្រូវធ្វើយូៗម្តងផងដែរ ។ វាគឺជាបំណងដើម្បីកំណត់រយៈពេលនៃការងារថែទាំយ៉ាងខ្លាំងក្នុងមួយឆ្នាំ ហើយគ្រប់សមាជិក FWUG ទាំងអស់គួរចូលរួមក្នុងការងារនេះ ។